# អនុក្រឹត្យលេខ ១៥ អនក្រ . បក
# ស្តីពីការកែសំរួលសមាសភាពគណៈកម្មាធិការជាតិរៀបចំ និងអនុវត្ត នយោបាយ កិច្ចការព្រៃឈើ

******

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១០៩៤ / ៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស / រកត / ១០៩៤ / ៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ០៨៩៧ / ១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ៣៣ អនក្រ . បក ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិ រៀបចំ និងអនុវត្តនយោបាយកិច្ចការព្រៃឈើ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សំរេច

**មាត្រា ១ .–** កែសំរួលមាត្រា២ នៃអនុក្រឹត្យលេខ ៣៣ អនក្រ . បក ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំ និងអនុវត្តនយោបាយកិច្ចការព្រៃឈើ ដែលមានសមាសភាពថ្មីដូចខាងក្រោម ៖

| | |
|---|---|
| ១- ឯកឧត្តម អ៊ឹង ហួត នាយករដ្ឋមន្ត្រីទី១ | សហប្រធាន |
| ២- សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី២ | សហប្រធាន |
| ៣- ឯកឧត្តម ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សហអនុប្រធាន |
| ៤- ឯកឧត្តម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សហអនុប្រធាន |
| ៥- ឯកឧត្តម សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦- ឯកឧត្តម សហរដ្ឋមន្ត្រីក្រសួងការពារជាតិ | សមាជិក |
| ៧- ឯកឧត្តម សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | សមាជិក |
| ៨- ឯកឧត្តម រដ្ឋមន្ត្រីក្រសួងផែនការ | សមាជិក |
| ៩- ឯកឧត្តម រដ្ឋមន្ត្រីក្រសួងបរិស្ថាន | សមាជិក |

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិរក្សសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)

១០- ឯកឧត្តម អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា ( គ.វ.ក ) សមាជិក

១១- លោកប្រធាន នាយកដ្ឋានរុក្ខាប្រមាញ់ លេខាធិការប្រតិបត្តិ

មាត្រា ២ ._ មាត្រាដទៃទៀត នៃអនុក្រឹត្យលេខ ៣៣ អនក្រ . បក ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំ និងអនុវត្តនយោបាយកិច្ចការព្រៃឈើ ត្រូវរក្សាទុកជាធរមានដដែល ។

មាត្រា ៣ ._ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងលោកប្រធាននាយកដ្ឋានរុក្ខាប្រមាញ់ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

អ៊ឹង ហួត ហ៊ុន សែន

***

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិរក្សសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)